ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ២២១៦៣ អពដ

# សារលិខិតជូនពរ

## សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា
## ក្នុងឱកាសច្រារព្ធខួបកំណើតគម្រប់ ៦៣ ឈានចូល ៦៤ ឆ្នាំ
## ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧

*សម្តេចកិត្តិព្រឹទ្ធបណ្ឌិតជាទីគោរពស្រលាញ់ដ៏ខ្ពង់ខ្ពស់ !*

ក្នុងឱកាសដ៏មង្គលសួស្តីប្រសើរថ្លៃថ្លា នៃពិធីខួបកំណើតគម្រប់ ៦៣ ឆ្នាំ ឈានចូល ៦៤ ឆ្នាំ របស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧ ខាងមុខ តាងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃអគ្គ-នាយកដ្ឋានពន្ធដារ ខ្ញុំបាទសូមសម្តែងនូវសេចក្តីអំណរសាទរឥតឧបមា និងសូមគោរពអនុញ្ញាតចូលរួមប្រសិទ្ធពរជ័យ បវរសួស្តី សិរីវឌ្ឍនា វិបុលសុខ មហាប្រសើរគ្រប់ប្រការ ជូនចំពោះ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំងសូមសម្តែងនូវសេចក្តីកោតសរសើរ យ៉ាងក្រៃលែង និងដឹងគុណមិនអាចបំភ្លេចបាន ចំពោះស្មារតី និងសកម្មភាពស្នេហាជាតិប្រកបដោយគតិបណ្ឌិត បញ្ញាញាណដ៏ថ្លៃថ្លា គំរូវីរភាពដ៏អង់អាចក្លាហាន ពោរពេញដោយគុណធម៌ មនុស្សធម៌ និងព្រហ្មវិហារធម៌យ៉ាងវិសេសវិសាល ដែលសម្តេចកិត្តិព្រឹទ្ធបណ្ឌិតតែងតែយកអស់នូវកម្លាំងកាយចិត្ត ប្រាជ្ញា ស្មារតី បទពិសោធ និងទេពកោសល្យដ៏ឧត្តុងឧត្តមប្រពៃថ្លៃថ្លា ក្នុងការលើកស្ទួយវប្បធម៌ សីលធម៌ ចរិយាធម៌របស់ស្ត្រីខ្មែរ ជាពិសេស ក្នុងបុព្វហេតុលើកស្ទួយជីវភាពរស់នៅរបស់ប្រជាជនខ្មែរគ្រប់កាលៈទេសៈ។

ជាថ្មីម្តងទៀត ឆ្លៀតក្នុងឱកាសដ៏មហាជ័យមង្គល សិរីសួស្តី ប្រពៃថ្លៃថ្លា វិសេសវិសាលនេះ ខ្ញុំបាទ យើងខ្ញុំទាំងអស់គ្នាសូមបួងសួងដល់ទេព្តាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក គុណបុណ្យព្រះរតនត្រ័យគុណកែវទាំងបី សូមព្រះអង្គតាមបីបាច់ថែរក្សា ប្រោះព្រំប្រទានសព្ទសាធុការពរជ័យ ជូន **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** និង**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បុត្រា-បុត្រី ចៅប្រុស-ចៅស្រី ជាទីស្រឡាញ់ សូមសមប្រកបដោយសុខភាពល្អបរិបូណ៌ កាយពលមាំមួន ប្រាជ្ញាវាងវៃ ជន្មាយុយឺនយូរ និងសមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** មេត្តាទទួលនូវអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់ និងភក្តីភាពដ៏ស្មោះស្ម័គ្របំផុត អំពីខ្ញុំបាទ យើងខ្ញុំទាំងអស់គ្នា។

រាជធានីភ្នំពេញ, ថ្ងៃព្រហស្បតិ៍ ១១រោច ខែមិគសិរ ឆ្នាំរកា ព.ស. ២៥៦១
ត្រូវនឹងថ្ងៃទី១៤ ខែធ្នូ គ.ស. ២០១៧
**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**